# សេចក្តីថ្លែងការណ៍រួម

## ក្រសួងបរិស្ថានគួរបញ្ឈប់ការចាប់ខ្លួន និងធ្វើទុក្ខបុកម្នេញសកម្មជនការពារព្រៃឈើ

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១

យើងខ្ញុំ ដែលមានរាយនាមដូចខាងក្រោម សូមស្នើសុំឱ្យក្រសួងបរិស្ថាន បញ្ឈប់យុទ្ធនាការនៃការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសកម្មជនការពារព្រៃឈើ និងសមាជិកសហគមន៍នៅតាមមូលដ្ឋាន ។ កាលពីព្រឹកថ្ងៃសុក្រសប្តាហ៍មុន មន្ត្រីមូលដ្ឋានរបស់ក្រសួងបរិស្ថាន បានឃាត់ខ្លួនសកម្មជនការពារព្រៃឈើ ចំនួន ៥នាក់ ដែលកំពុងបំបួសដើមឈើ និងប្រមូលភស្តុតាងនៃការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ដែលកើតមាននៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ ។

អ្នកទាំង៥នាក់ ត្រូវបានឃាត់ខ្លួនដោយគ្មានការចោទប្រកាន់អស់រយៈពេល៣យប់ នៅមន្ទីរបរិស្ថាន និងអធិការដ្ឋាននគរបាលក្រុងក្រចេះ មុនពេលត្រូវបានដោះលែងឱ្យមានសេរីភាពវិញនៅព្រឹកថ្ងៃចន្ទនេះ ។ សកម្មជនទាំង៥នាក់ ត្រូវបានដោះលែងវិញ បន្ទាប់ពីផ្តិតមេដៃលើកិច្ចសន្យាដែលហាមឃាត់ពួកគាត់មិនឱ្យធ្វើសកម្មភាពអភិរក្សផ្សេងៗនៅក្នុងតំបន់ការពារធម្មជាតិ ឬចែករំលែកវីដេអូ រូបភាព ឬព័ត៌មានឱ្យអង្គភាពខាងក្រៅ ប្រសិនបើគ្មានការអនុញ្ញាតពីអាជ្ញាធរ ។

នេះមិនមែនជាលើកទីមួយទេ ដែលសកម្មជនទាំងនេះត្រូវបានឃាត់ខ្លួន ។ នៅពេលពិនិត្យមើលជារួមក្នុងការបង្ក្រាបរបស់ក្រសួងបរិស្ថានលើកមុនទៅលើ ព្រឹត្តិការណ៍បែបសហគមន៍មូលដ្ឋានដើម្បីការពារព្រៃឡង់កាលពីឆ្នាំមុន យើងខ្ញុំព្រួយបារម្ភយ៉ាងខ្លាំងថា សកម្មភាពមួយចំនួនរបស់ក្រសួងប្រឆាំងនឹងសកម្មជនមូលដ្ឋានគឺមិនត្រឹមតែមិនបានជួយការពារព្រៃចុងក្រោយនេះទេ ប៉ុន្តែផ្ទុយទៅវិញបែរជាធ្វើទុក្ខទោសដល់ការខិតខំប្រឹងប្រែងអភិរក្សទៅទៀត ជាពិសេសនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់នេះតែម្តង ។

សកម្មជនដែលត្រូវបានឃាត់ខ្លួន ក្នុងនោះមានលោក អ៊ួច ឡេង ដែលបានឈ្នះពានរង្វាន់វីរជនបរិស្ថានពិភពលោក (Goldman Environmental Prize) ត្រូវបានឃាត់ខ្លួនកាលពីថ្ងៃសុក្រនៅក្នុងដែនជម្រកសត្វព្រៃខេត្តក្រចេះ ។ សម្ភារៈដែលអាជ្ញាធរបានដកហូតយកពីអ្នកទាំង៥នាក់ ដើម្បីធ្វើជា“ភស្តុតាង”រួមមាន ផ្ទាំងបដាផ្សព្វផ្សាយដែលសរសេរថា “សូមជួយថែរក្សាព្រៃឈើយើង” ម៉ាស៊ីនថត ឧបករណ៍

ចាប់ទីតាំង (GPS) និងអង្គចងចាំ ដែលសកម្មជនទាំងនេះបានអះអាងថា មានភស្តុតាងនៃការកាប់បំផ្លាញព្រៃឈើខុសច្បាប់ ។

ច្បាស់ណាស់ថា សម្ភារៈទាំងនេះមិនមែនជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើសណាមួយទេ ។ ផ្ទុយទៅវិញ សម្ភារៈទាំងនេះបង្ហាញថាសកម្មជនទាំង៥នាក់ រួមមាន លោក អ៊ុច ឡេង លោក ហេង ស្រស់ លោក ម៉ាន ម៉ាត់ លោក ហេង វ៉ុន និងលោក ឥង ជាង កំពុងតែធ្វើការដើម្បីការពារព្រៃឡង់ពីការកើនឡើងនៃការកាប់បំផ្លាញព្រៃចុងក្រោយនេះ ក៏ដូចជាចងក្រងឯកសារជាភស្តុតាងនៃការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅតំបន់នោះ ។

ក្រសួងបរិស្ថានបានចោទប្រកាន់អ្នកទាំង៥នាក់ថា “បានចូលក្នុងតំបន់ការពារធម្មជាតិដោយគ្មានការអនុញ្ញាត” ។ ការចោទប្រកាន់នេះ ធ្វើឡើងដោយគ្មានមូលដ្ឋានច្បាប់នៅកម្ពុជា ។ ការបដិសេធមិនឱ្យចូលទៅកាន់តំបន់ការពារធម្មជាតិគឺអាចធ្វើឡើងសម្រាប់តំបន់ជាក់លាក់ដែលបានកំណត់រួចរាល់ថាជា “តំបន់ស្នូល” ដែលព្រៃឡង់មិនទាន់ត្រូវបានកំណត់ទេ ។ ជារឿងគួរឱ្យសោកស្តាយ នេះមិនមែនជាលើកទីមួយទេដែលក្រសួងបានបដិសេធសកម្មជនការពារព្រៃឈើ មិនឱ្យចូលក្នុងដែនជម្រកសត្វព្រៃនេះដូចធម្មតា ។

កាលពីខែកុម្ភៈ ឆ្នាំមុន មន្ត្រីក្រសួងបរិស្ថានបានបញ្ឈប់ព្រះសង្ឃ សមាជិកសហគមន៍ និងសកម្មជនបរិស្ថាន រាប់រយនាក់នៃបណ្តាញសហគមន៍ព្រៃឡង់ ពីការចូលទៅកាន់ព្រៃឡង់ ដើម្បីប្រារព្ធពិធីបុណ្យបំបួសដើមឈើប្រចាំឆ្នាំ ដោយអះអាងថា អ្នកទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់តំបន់ការពារធម្មជាតិទេ ។ រយៈពេលមួយខែក្រោយមក មន្ត្រីមូលដ្ឋានបានឃាត់ខ្លួនសកម្មជនការពារព្រៃឈើចំនួន៤នាក់រួមមាន លោក អ៊ុច ឡេង និងលោក ម៉ាន ម៉ាត់ ដែលកំពុងធ្វើរបាយការណ៍ស៊ើបអង្កេតពីការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅព្រៃឡង់ ។ ការចាប់ខ្លួនទាំងនេះកើតឡើងបន្ទាប់ពីពួកគាត់ត្រូវបានវាយដំដោយសន្តិសុខធ្វើការឱ្យ ក្រុមហ៊ុនស៊ីងបាយអូថេក ជាក្រុមហ៊ុនដែលមានដីសម្បទាន ៣៤០០០ ហិចតា ស្ថិតនៅជាប់ដែនជម្រកសត្វព្រៃព្រៃឡង់ និងត្រូវបានរងការចោទប្រកាន់ពីសំណាក់សមាជិកសហគមន៍មូលដ្ឋាន ពាក់ព័ន្ធនឹងការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិ ។

ការកាប់បំផ្លាញព្រៃឈើខុសច្បាប់នៅក្នុងតំបន់ការពារធម្មជាតិគឺជាបញ្ហាកើតមានឥតឈប់ឈរមួយនៅកម្ពុជា ហើយយើងត្រូវការជាខ្លាំងនូវការចូលរួមរបស់មនុស្ស និងស្ថាប័នផ្សេងៗគ្នា រួមមានក្រសួងបរិស្ថាន អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងអង្គការនៅក្នុងកម្រិតសហគមន៍មូលដ្ឋានដើម្បីធ្វើការដោយសេរី និងឯករាជ្យ ក្នុងការការពារព្រៃឈើដែលនៅសេសសល់របស់យើងទាំងអស់គ្នា ។

យើងខ្ញុំ សូមសម្តែងការសោកស្តាយ ដែលក្រសួងបានចូលរួមនៅក្នុងយុទ្ធនាការនៃការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងសកម្មជនការពារព្រៃឈើដ៏មានប្រជាប្រិយភាពមួយចំនួននៅក្នុងប្រទេស ។ ដោយការពិនិត្យមើលជារួម សកម្មភាពទាំងនេះ ក៏ដូចជាផែនការដែលទើបត្រូវបានរាយការណ៍ថ្មីៗនេះ ក្នុងការសាងសង់ បណ្តាញខ្សែអគ្គិសនី និងផ្លូវអមបណ្តាញនោះ ដោយឆ្លងកាត់ចំណុចសំខាន់នៃព្រៃឡង់ពិតជាធ្វើឱ្យយើងខ្ញុំមានការព្រួយបារម្ភជាខ្លាំង ។

ព្រៃឡង់គឺត្រូវបានកំណត់ជា "តំបន់ការពារធម្មជាតិ" ផ្អែកតាមច្បាប់កម្ពុជា ។ សកម្មជនទាំង៥នាក់ដែលត្រូវបានឃាត់ខ្លួន ក៏ដូចជាយើងខ្ញុំទាំងអស់គ្នា គ្រាន់តែចង់ឃើញដែនជម្រកសត្វព្រៃ នៅរក្សាស្ថានភាព ជា "តំបន់ការពារ" ដូចដែលច្បាប់បានកំណត់ ។ យើងខ្ញុំ សូមស្នើសុំដោយទទូចដល់ក្រសួងបរិស្ថាន ឱ្យបញ្ឈប់ការធ្វើទុក្ខបុកម្នេញចំពោះសកម្មជន និងគោរពសិទ្ធិរបស់គ្រប់ភាគីទាំងអស់ដែលមានបំណងចង់ឃើញ ព្រៃឡង់ ត្រូវបានអភិរក្ស និងការពារ ឱ្យបានយូរអង្វែងបន្តទៀត ៕

**សេចក្តីថ្លែងការណ៍នេះ គាំទ្រដោយ៖**

១. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
២. សកម្មភាពដើម្បីបរិស្ថាន និងសហគមន៍ (AEC)
៣. ក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)
៤. សម្ព័ន្ធគណនេយ្យភាពសង្គម កម្ពុជា (ANSA)
៥. សហគមន៍អមលាំង (កំពង់ស្ពឺ)
៦. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
៧. សហគមន៍បឹងប្រាំ (បាត់ដំបង)
៨. អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ (BCV)
៩. សហគមន៍បុស្សស្មោរ (ត្បូងឃ្មុំ)

១០. សម្ព័ន្ធសហជីពកម្ពុជា (CATU)
១១. សមាគមអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជា (CDPLA)
១២. សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
១៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា អាដហុក (ADHOC)
១៤. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
១៥. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា (CICA)
១៦. សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
១៧. សមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ (CITA)
១៨. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ (CIWA)
១៩. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
២០. សហភាពការងារកម្ពុជា (CLC)
២១. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា (CTWUF)
២២. សហព័ន្ធសហជីពវិស័យទេសចរណ៍សេវាកម្មកម្ពុជា (CTSWF)
២៣. បណ្តាញយុវជនកម្ពុជា (CYN)
២៤. បណ្តាញព្រះសង្ឃយុវជនកម្ពុជា (CYMN)
២៥. អនាគតយុវជនកម្ពុជាអាស៊ាន (CamASEAN)
២៦. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
២៧. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
២៨. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
២៩. សហគមន៍ដីធ្លីជីខលើ (កោះកុង)
៣០. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ (រតនគិរី)
៣១. សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
៣២. សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)
៣៣. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)
៣៤. បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
៣៥. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)

៣៦. សហគមន៍ដក់ពរ (កំពង់ស្ពឺ)

៣៧. អង្គការសមធម៌កម្ពុជា (EC)

៣៨. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

៣៩. សហគមន៍ហោងសំណំ (កំពង់ស្ពឺ)

៤០. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

៤១. សហគមន៍ជនជាតិដើមភាគតិចឃុំប្រមេរុខេត្តព្រះវិហារ

៤២. សហព័ន្ធសហជីពឯករាជ្យ (INTUFE)

៤៣. សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA)

៤៤. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)

៤៥. សហគមន៍នេសាទកោះស្រឡៅ (កោះកុង)

៤៦. សហគមន៍ជនជាតិភាគតិចគួយ (ព្រះវិហារ)

៤៧. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនកាស៊ីណូ ណាហ្គាវើល

៤៨. សហគមន៍ដីធ្លីខេត្តប៉ៃលិន

៤៩. សហគមន៍ឡពាង (កំពង់ឆ្នាំង)

៥០. សហគមន៍មានជ័យ (ស្វាយរៀង)

៥១. មាតាធម្មជាតិកម្ពុជា (MNC)

៥២. Not 1 More (N1M)

៥៣. សហគមន៍អូរល្ពៅព្រែង (បាត់ដំបង)

៥៤. អង្គការស្ពានសន្តិភាព (PBO)

៥៥. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (PDP)

៥៦. សហគមន៍ដីធ្លីភូមិផ្សារកណ្ដាល (បន្ទាយមានជ័យ)

៥៧. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)

៥៨. សហគមន៍ភ្នំក្រោម (សៀមរាប)

៥៩. អង្គការពន្លកខ្មែរ (PKH)

៦០. សហគមន៍ដីធ្លីព្រែកខ្សាច់ (កោះកុង)

៦១. សហគមន៍ព្រៃឈើពេជ្រចង្វារល្អឆើត (កំពង់ឆ្នាំង)

៦២. សហគមន៍ព្រៃឡង់ (កំពង់ធំ)

៦៣. សហគមន៍ដីធ្លីព្រៃពាយ (កំពត)

៦៤. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)

៦៥. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)

៦៦. អង្គការគាំទ្របច្ចេកវិទ្យានៅជនបទក្នុងប្រទេសកម្ពុជា (RCTSO)

៦៧. សហគមន៍សាមគ្គីរមាសហែក (ស្វាយរៀង)

៦៨. សហគមន៍សាមគ្គីសង្ហៃពីរមានរិទ្ធិ (ព្រះវិហារ)

៦៩. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)

៧០. សហគមន៍ដីធ្លីតានូន (កោះកុង)

៧១. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)

៧២. សហគមន៍ថ្មដា (ពោធិ៍សាត់)

៧៣. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)

៧៤. អង្គការតម្លាភាពកម្ពុជា (TI)